# ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងការអប់រំ៖ ការសិក្សាប្រៀបធៀបរវាងបួនប្រទេស

## សេចក្ដីផ្ដើម

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស (tracking) គឺការអនុវត្តដាក់សិស្សចូលទៅក្នុងផ្នែកសិក្សា កម្មវិធីសិក្សា ឬ សាលាខុសៗគ្នា ដោយផ្អែកលើសមត្ថភាព លទ្ធផលសិក្សា និង ចំណាប់អារម្មណ៍របស់ពួកគេ។ ការអនុវត្តបែបនេះ ផ្ដល់លទ្ធភាពឲ្យគ្រូអាចរៀបចំការបង្រៀន ស្របទៅតាមតម្រូវការរបស់សិស្ស (Chmielewski, Dumont and Trautwein 2013, 926) ដោយមិនសូវបារម្ភថា ទៅចោលសិស្សដែលរៀនយឺត ឬក៏មិនបានជួយជំរុញគ្រប់គ្រាន់ដល់សិស្សដែលរៀនលឿន ។

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស (tracking) ត្រូវគេអនុវត្តតាមទម្រង់ខុសៗគ្នា ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ។ ក្នុងនោះ ប្រទេសអាឡឺម៉ង់ និង ហុងគ្រី ធ្វើការបែងចែកសិស្ស តាំងពីអាយុ ១០ឆ្នាំ រីឯប្រទេសអង់គ្លេស ជប៉ុន និងសហរដ្ឋអាមេរិកវិញ ច្រើនទុកឲ្យសិស្សរៀនគ្រប់មុខវិជ្ជាទូទៅរហូតដល់ កម្រិតអនុវិទ្យាល័យ ទើបធ្វើការបែងចែកសិស្សនៅថ្នាក់វិទ្យាល័យ។ អត្ថបទនេះ ធ្វើការប្រៀបធៀបការអនុវត្តការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងប្រទេសចំនួនបួននៅអាស៊ី រួមមាន៖ សិង្ហបុរី កូរ៉េខាងត្បូង វៀតណាម និង កម្ពុជា ដើម្បីរៀនសូត្រពីបទពិសោធន៍ផ្សេងៗ សម្រាប់យកមកកែលំអរបៀបអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅកម្ពុជា។

## វិធីសាស្ត្រ

អត្ថបទនេះ ផ្អែកជាចម្បងលើឯកសារផ្សេងៗ ដូចជា របាយការណ៍ស្រាវជ្រាវដែលមានស្រាប់ និងគោលនយោបាយអប់រំរបស់ប្រទេសដែលយកមកសិក្សា។ បន្ថែមលើឯកសារសិក្សាស្រាវជ្រាវមានស្រាប់ មានព័ត៌មានផ្សេងទៀតដែលទទួលបានពីកិច្ចសន្ទនាក្រៅផ្លូវការរបស់អ្នកស្រាវជ្រាវជាមួយ គ្រូគីមីវិទ្យាម្នាក់នៅវិទ្យាល័យមួយនៅកម្ពុជា និងសហសេវិករបស់អ្នកស្រាវជ្រាវនៅ វៀតណាម និង កូរ៉េខាងត្បូង។

សិង្ហបុរី និងកូរ៉េខាងត្បូង បានទទួលជោគជ័យក្នុងការរៀបចំប្រព័ន្ធអប់រំបែបទំនើបរបស់ខ្លួន ដូច្នេះបទពិសោធន៍របស់ប្រទេសទាំងពីរ ក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស មានអត្ថប្រយោជន៍សម្រាប់កម្ពុជា។ ទោះបីជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍក្ដី វៀតណាមសម្រេចបានគុណភាពអប់រំ លើសពីការរំពឹងទុករបស់ពិភពលោក ដោយទទួលបានពិន្ទុមធ្យម (mean score) ៥១១ ក្នុងការចូលរួមធ្វើតេស្តលើកដំបូងនៅឆ្នាំ២០១២ ក្នុងកម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ (PISA) ធៀបនឹង ពិន្ទុមធ្យម (average score) ៤៩៤ របស់បណ្ដាប្រទេសនៃ អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD 2014) ។

## បទដ្ឋានពទូទៅក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សនៅក្នុងប្រទេសនីមួយៗ

### *សិង្ហបុរី*

សិង្ហបុរីបានអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស តាំងពីឆ្នាំ១៩៧៩ មក ដោយបែងចែកសិស្សតាំងពីថ្នាក់បឋមសិក្សាឡើងទៅ ឲ្យចូលក្នុងផ្នែកសិក្សាខុសៗគ្នា តាមរយៈការប្រឡង ការធ្វើតេស្ត និង របាយការណ៍ របស់សាលារៀន (Kam and Gopinathan 1999, 103)។ ដោយយល់ច្បាស់ពីភាពខុសគ្នាក្នុងការលូតលាស់ និងលទ្ធភាពទទួលបានលទ្ធផលអប់រំ គោលគំនិតក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស លើសិស្សថ្នាក់ទី៥ និង ៦ នេះ គឺដើម្បីឲ្យសិស្សអាចប្រើសក្ដានុពលរបស់ខ្លួនយ៉ាងពេញលេញ(OECD 2011)។

ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សបច្ចុប្បន្ននេះ ត្រូវបានកែលំអទៅជាការដាក់ចូលក្រុមតាមមុខវិជ្ជា (subject-based banding)។ ការដាក់តាមមុខវិជ្ជានេះ អាចជួយឲ្យសិស្សស្វែងយល់ពីសក្ដានុពល តាមរយៈចំណូលចិត្ត និង ចំណុចខ្លាំងរបស់ខ្លួន ហើយវិធីនេះក៏ផ្ដល់លទ្ធភាពអាចបត់បែនបានច្រើន តាមរយៈការផ្ដល់ជម្រើសដល់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាគួបផ្សំមូលដ្ឋានគ្រឹះ និងមុខវិជ្ជាស្ដង់ដា (MOEofSingapore 2016a)។ ឧទាហរណ៍ សិស្សពូកែខាងភាសា (អង់គ្លេស ចិន ម៉ាឡេ ឬតាមិល) ប៉ុន្តែខ្សោយខាងគណិតវិទ្យា និង វិទ្យាសាស្ត្រ អាចជ្រើសយកមុខវិជ្ជាភាសាពីរមករៀនតាមកម្រិតស្ដង់ដា ហើយយកគណិតវិទ្យា និងវិទ្យាសាស្ត្រមករៀនតាមកម្រិតមូលដ្ឋានគ្រឹះ។ សាលារៀនជួយផ្ដល់យោបល់ពីការគួបផ្សំមុខវិជ្ជា ដោយផ្អែកលើលទ្ធផលប្រឡងនៅថ្នាក់ទី៤ ហើយឪពុកម្ដាយ អាចបំពេញនូវទម្រង់ឯកសារមួយ ដើម្បីបញ្ជាក់ពីមុខវិជ្ជាដែលគាត់ចង់ជ្រើសរើសឲ្យកូនរៀន។ នៅថ្នាក់ទី៥ សិស្សរៀនតាមមុខវិជ្ជាគួបផ្សំដែលឪពុកម្ដាយបានជ្រើសរើស។ នៅចុងឆ្នាំថ្នាក់ទី៥នោះ សាលារៀនវាយតម្លៃលើសមត្ថភាពសិស្ស ក្នុងការរៀនតាមមុខវិជ្ជាដែលបាន

---

អត្ថបទនេះរៀបរៀងឡើងដោយ អេង សុខា អ្នកហាត់ការក្នុងផ្នែកអប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា Eng Sokha. 2017. "Tracking in Education: A Four Country Comparative Study." *Cambodia Development Review* 21(2) 12-16. ភ្នំពេញ វិទ្យាស្ថាន CDRI។

ជ្រើស។ នៅថ្នាក់ទី៦ សិស្សត្រូវរៀនតាមមុខវិជ្ជាគួបផ្សំដែលសាលារៀនបានផ្ដល់យោបល់ ហើយប្រឡងបញ្ចប់បឋមសិក្សាថ្នាក់ជាតិ (PSLE) (MOE of Singapore 2016a)។

នៅថ្នាក់មធ្យមសិក្សា ដោយផ្អែកតាមលទ្ធផលប្រឡង PSLE គេដាក់សិស្ស ចូលក្នុងផ្នែកសិក្សាមួយក្នុងចំណោម ផ្នែកសិក្សាទាំង ៣ គឺ ផ្នែកលឿន ផ្នែកធម្មតា (ការសិក្សាអប់រំទូទៅ) និងផ្នែកធម្មតា (បច្ចេកទេស)។ ភាពខុសគ្នារវាង ផ្នែកលឿន នឹងផ្នែកធម្មតា (សិក្សាអប់រំទូទៅ) គឺផ្នែកលឿនបង្រៀនមុខវិជ្ជាកម្រិតខ្ពស់ជាងដោយប្រើភាសាកំណើត។ សិស្សនៅក្នុងផ្នែកធម្មតា (បច្ចេកទេស) ត្រូវរៀនពីការប្រើប្រាស់កុំព្យូទ័រជាមុខវិជ្ជាចាំបាច់ព្រមទាំងភាសាអង់គ្លេស ភាសាកំណើតមួយ និងគណិតវិទ្យា (MOE of Singapore 2016b)។ ប្រព័ន្ធអប់រំថ្នាក់មធ្យមសិក្សារបស់សិង្ហបុរី ផ្ដល់លទ្ធភាពបត់បែនបានច្រើន ដោយអនុញ្ញាតឲ្យសិស្សអាចផ្លាស់ប្ដូរពីផ្នែកសិក្សាមួយ ទៅផ្នែកមួយផ្សេងទៀត ដោយផ្អែកតាមលទ្ធផលសិក្សា និងការវាយតម្លៃរបស់គ្រូ និងនាយកសាលា។

### *កូរ៉េខាងត្បូង*

ប្រព័ន្ធអប់រំកូរ៉េខាងត្បូង ផ្ដល់នូវការសិក្សាគ្រប់មុខវិជ្ជាទូទៅរហូតដល់ថ្នាក់ទី១០ (Nuffic 2013) ដើម្បីធានាថា សិស្សទាំងអស់ទទួលបានចំណេះដឹងនិងជំនាញជាមូលដ្ឋានដែលខ្លួនត្រូវការសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ។ ចាប់ពីថ្នាក់ទី១១ ឡើងទៅ មានការបែងចែកវិទ្យាល័យជា ២ប្រភេទគឺ វិទ្យាល័យទូទៅ សម្រាប់អ្នកចង់បន្តទៅថ្នាក់ឧត្ដមសិក្សា និងវិទ្យាល័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ[1] សម្រាប់អ្នកចង់ចូលធ្វើការ ក្រោយពេលបញ្ចប់វិទ្យាល័យ (Kim, J-H. Lee and Y. Lee 2003, 5)។ នៅវិទ្យាល័យទូទៅមានការបែងចែកជា ផ្នែកវិទ្យាសាស្ត្រ និងផ្នែកមនុស្សសាស្ត្រ ហើយការបែងចែកនេះ ធ្វើឡើងដោយមិនផ្អែកលើសមត្ថភាពសិស្សនោះទេ តែធ្វើឡើងទៅតាមមុខវិជ្ជា ដើម្បីត្រៀមខ្លួនសិស្សដែលចង់រៀនបន្តខាងវិទ្យាសាស្ត្រ វិស្វកម្ម ឬវិទ្យាសាស្ត្រសង្គមនៅសាកលវិទ្យាល័យ។ សិស្សនៅតាមផ្នែកសិក្សាខុសៗគ្នាក្នុងសាលាតែមួយ និងសិស្សម្នាក់ៗ ត្រូវរៀនតាមផ្នែកសិក្សាដែលបានកំណត់ជាមុនទាំងនេះដូចៗគ្នា ដោយគ្មានការផ្លាស់ប្ដូរថ្នាក់រៀនទេ (Kim, J-H. Lee and Y. Lee 2003, 5)។ កូរ៉េខាងត្បូងក៏មានវិទ្យាល័យពិសេស សម្រាប់ផ្ដល់កម្មវិធីសិក្សាដល់សិស្សឆ្នើមខាងវិទ្យាសាស្ត្រធម្មជាតិ និងគណិតវិទ្យា ដែរ។ ឧទាហរណ៍ សិស្សទាំងនេះអាចប្រឡងជាប់ក្នុងកម្មវិធីសិក្សារយៈពេល២ឆ្នាំនៅវិទ្យាល័យ Seoul Science ហើយបន្តការសិក្សានៅតាមសាកលវិទ្យាល័យ ឬវិទ្យាស្ថានល្បីៗបាន (Choi and D-S.Hon 2009, 45)។[2]

កម្មវិធីសិក្សា អនុញ្ញាតឲ្យសិស្សជ្រើសរើសផ្នែកសិក្សាបាននៅថ្នាក់ទី១១។ សិស្សដែលជ្រើសយកផ្នែកមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម អាចជ្រើសយកមុខវិជ្ជា ដូចជា ភាសាកូរ៉េ ការអប់រំសីលធម៌ និងការសិក្សាសង្គម ហើយសម្រាប់សិស្សខាងផ្នែកវិទ្យាសាស្ត្រ អាចជ្រើសរៀនមុខវិជ្ជា ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា។ ម្យ៉ាងទៀត សិស្សគ្រប់គ្នាត្រូវរៀនចប់មុខវិជ្ជាស្នូលចាំបាច់មួយចំនួន (MOEST Korea 2008) ។ ដូច្នេះ ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅកូរ៉េខាងត្បូង អនុញ្ញាតឲ្យមានភាពលាយចម្រុះគ្នាមួយកម្រិតនៅក្នុងថ្នាក់រៀន និងការផ្ទេរ ឬការចែករំលែកចំណេះដឹងរវាងសិស្សនានា។ ទោះយ៉ាងណា ការផ្លាស់ប្ដូរគំនិត ឬការចែករំលែក/ផ្ទេរចំណេះដឹង អាចកើតមានតែក្នុងថ្នាក់រៀនមុខវិជ្ជាចាំបាច់ ដូចជា ភាសាបរទេស ជាដើម និងក្នុងមុខវិជ្ជាកម្រិតខ្ពស់ៗនៅតាមផ្នែកសិក្សានីមួយៗ។ ឧទាហរណ៍ សិស្សដែលបានជ្រើសយកផ្នែកសិក្សាសង្គម គឺមានឱកាសតិចតួចណាស់ក្នុងការរៀនមុខវិជ្ជាវិទ្យាសាស្ត្រខ្ពស់ៗ។

### *វៀតណាម*

វៀតណាមផ្ដល់កម្មវិធីអប់រំ ដែលកំណត់ឲ្យសិស្សរៀនគ្រប់មុខវិជ្ជាទូទៅដល់ថ្នាក់ទី៩ (UNESCO 2007) ហើយវៀតណាមបានដាក់អនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សជាលើកដំបូងនៅឆ្នាំសិក្សា២០០៦/២០០៧ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ដើម្បីផ្ដល់ជម្រើសឲ្យបានកាន់តែធំទូលាយ កម្មវិធីសិក្សាត្រូវបានចែកចេញជា ៣ ផ្នែករួមមាន វិទ្យាសាស្ត្រពិត បច្ចេកវិទ្យា និងវិទ្យាសាស្ត្រសង្គមនិងភាសាបរទេស។ នាយក ឬក្រុមប្រឹក្សាសាលារៀន អាចសម្រេចចិត្តថា សាលារៀនគួរផ្ដល់ការសិក្សាប៉ុន្មានផ្នែក និងគួរជ្រើសយកផ្នែកណាខ្លះ បន្ទាប់ពីទទួលបានការយល់ព្រមពី មន្ទីរអប់រំ និងបណ្ដុះបណ្ដាលថ្នាក់ខេត្ត (Fredriksen and Peng 2008)។ លក្ខខណ្ឌលើផ្នែកសិក្សាទាំង ៣ នេះ គឺតម្រូវឲ្យសិស្សមានស្តង់ដានៃចំណេះដឹង ឬជំនាញសម្រាប់មុខវិជ្ជាក្នុងកម្មវិធីសិក្សាទាំងអស់។ ឧទាហរណ៍ ដើម្បីរៀនខាងវិទ្យាសាស្ត្រធម្មជាតិ សិស្សត្រូវសម្រេចបានពិន្ទុ កម្រិតខ្ពស់ខាងរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និង គណិតវិទ្យា នៅពេលប្រឡងចូល។ សិស្សក្នុងផ្នែកសិក្សានីមួយៗ ត្រូវរៀនដូចគ្នានូវមុខវិជ្ជាកាតព្វកិច្ច (ឧទាហរណ៍ សិល្បៈ ការអប់រំពលរដ្ឋ ភាសាបរទេស ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ គណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា កីឡា និងការអប់រំយោធា) ដោយមានពេល ៦ម៉ោងក្នុងមួយសប្ដាហ៍ សម្រាប់រៀនមុខវិជ្ជាដែលខ្លួនបានជ្រើសរើស (WES 2012)។

### *កម្ពុជា*

សាលារៀននៅកម្ពុជា អនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ពីថ្នាក់ទី១១ ដោយមានផ្ដល់ ២ផ្នែកសិក្សា គឺមាន វិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ប្រព័ន្ធនៃ

1 ក្នុងអត្ថបទនេះ វិទ្យាល័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ មិនមានលើកយកមកពិភាក្សាទេ។

2 វិទ្យាល័យពិសេស ទាំងរដ្ឋ និងឯកជន មានស្វ័យភាពជ្រើសរើសសិស្ស រចនារៀបចំកម្មវិធីសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យក្នុងការចូលរៀន។

ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សបានអនុវត្តឡើង ដើម្បីផ្តល់ឱកាសឲ្យសិស្ស ពង្រឹងពង្រីកចំណាប់អារម្មណ៍ និងរៀបចំកម្មវិធីសិក្សារបស់ខ្លួន ដោយអាចជ្រើសយកបានដល់ ៤ មុខវិជ្ជា នៅក្នុងផ្នែកសិក្សាទាំង ២ នេះ (MOEYS 2004)។ ខាងផ្នែកវិទ្យាសាស្ត្រមានបង្រៀន គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា ផែនដីវិទ្យា និងការសិក្សាពីបរិស្ថាន ហើយខាងផ្នែកសិក្សាសង្គមមានបង្រៀន ក្រមសីលធម៌ ពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា សេដ្ឋកិច្ច និងភូមិវិទ្យា។ សិស្សទាំងអស់ត្រូវសិក្សាមុខវិជ្ជាកាតព្វកិច្ចចំនួន ៤ គឺអក្សរសាស្ត្រខ្មែរភាសាបរទេស (អង់គ្លេសឬបារាំង) គណិតវិទ្យាជាមូលដ្ឋាន (៤ ម៉ោង/សប្តាហ៍) ឬគណិតវិទ្យាកម្រិតខ្ពស់ (៨ ម៉ោង/សប្តាហ៍) ហើយនិង ការអប់រំកាយនិងសុខភាព និងកីឡា។

ដូចនៅកូរ៉េខាងត្បូង និងវៀតណាមដែរ កម្ពុជាបានអនុញ្ញាតឲ្យសាលារៀនអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ដូច្នេះសិស្សអាចរៀនថ្នាក់ខុសៗគ្នា ទៅតាមសមត្ថភាព និងមុខវិជ្ជាបានជ្រើសយក។ សិង្ហបុរី និង វៀតណាម បែងចែកសិស្សទៅតាមសមត្ថភាព លទ្ធផលប្រឡង និងពិន្ទុតាមមុខវិជ្ជា រីឯកម្ពុជា គឺដូចគ្នានឹងកូរ៉េខាងត្បូងដែរ បែងចែកជាសំខាន់ទៅតាមចំណាប់អារម្មណ៍របស់សិស្ស។

## ការពិភាក្សា និងការអនុវត្ត

សិង្ហបុរីជាប្រទេសនាំមុខគេមួយក្នុងវិស័យអប់រំ ហើយស្ថិតនៅលំដាប់កំពូលៗ នៅក្នុងចំណាត់ថ្នាក់ការអប់រំសំខាន់ៗក្នុងពិភពលោក។ តាមការវាយតម្លៃលើសមត្ថភាពដោះស្រាយបញ្ហាក្នុងឆ្នាំ២០១២ របស់ PISA សិស្សសិង្ហបុរី បានលទ្ធផលល្អជាពិសេស ក្នុងការទាញយកចំណេះដឹង និងការធ្វើការរួមគ្នានិងទំនាក់ទំនងក្នុងក្រុម (OECD 2014)។ ជោគជ័យប្រកបដោយចីរភាពរបស់ប្រទេសនេះ អាចបណ្តាលមកពីកត្តាជាច្រើន ដូចជាការបន្សីគ្នាយ៉ាងល្អរវាងគោលនយោបាយ នឹងការអនុវត្ត ការជ្រើសរើសគ្រូបង្រៀន និងនាយកសាលាមានគុណភាពខ្ពស់ និងការផ្តោតលើការអភិវឌ្ឍវិជ្ជាជីវៈ និងការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឲ្យមានការកែលំអគុណភាពជាប្រចាំ។ ម្យ៉ាងទៀត ការចាប់បង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រកម្រិតមូលដ្ឋាន តាំងពីថ្នាក់បឋមសិក្សា បានផ្តល់ឲ្យកុមារនូវគ្រឹះដ៏រឹងមាំ សម្រាប់ការទទួលបានជោគជ័យនៅក្នុងសាលារៀន (OECD 2011)។

គួរកត់សំគាល់ថា ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ក្នុងប្រព័ន្ធអប់រំនៅសិង្ហបុរី ដែលអនុញ្ញាតឲ្យសិស្សជ្រើសយកផ្នែកសិក្សាខុសៗគ្នានោះ បានជួយកាត់បន្ថយអត្រាបោះបង់ការសិក្សា កែលំអគុណភាពអប់រំ និងកសាងជំនាញមួយចំនួន ដែលមានតម្រូវការចាំបាច់នៅក្នុងសេដ្ឋកិច្ចប្រើមូលធន និងជំនាញច្រើន (OECD 2016)។ ទោះបី ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស អនុញ្ញាតឲ្យសាលារៀនបង្កើតកម្មវិធីសិក្សាដើម្បីបំពេញតាមតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សក្តី ពីដំបូងមានការរិះគន់ថា អាចមាន "ឥទ្ធិពលអាក្រក់ទៅលើសន្ទុះចិត្ត និងការដឹងស្គាល់ពីខ្លួនឯងរបស់សិស្ស ដែលផុសចេញពីដំណើរការបែងចែកមុខវិជ្ជាសិក្សា" (Kam and Gopinathan 1999, 113)។ សរុបមក ក្នុងការរៀនសូត្រពីប្រព័ន្ធអប់រំនៅសិង្ហបុរី គេត្រូវគិតដល់ឧត្តមភាពរបស់ប្រទេសនេះ ក្នុងលក្ខណៈជាទីក្រុងមួយដ៏តូច ដែលមានរដ្ឋាភិបាលមួយយ៉ាងធំ បណ្តាញសង្គមរឹងមាំ និងអារម្មណ៍ជាផ្នែកមួយនៃសហគមន៍។

កំណើនវិនិយោគនៃរដ្ឋាភិបាលក្នុងការអប់រំ និងការប្រើប្រាស់ជំនួយបរទេសដ៏មានប្រសិទ្ធភាព ដែលជាដំបូងផ្តោតលើការអប់រំកម្រិតបឋមសិក្សាជាសាកល និងបន្ទាប់មកលើមធ្យមសិក្សា ដើម្បីបំពេញតាមតម្រូវការទីផ្សារពលកម្មនោះ បានអនុញ្ញាតឲ្យកូរ៉េខាងត្បូង អាចពង្រឹងជាបណ្តើរៗនូវគុណភាពរបស់គ្រូបង្រៀន ការបង្រៀន និងសាលារៀន។ ក្នុងឆ្នាំ១៩៥៤ រដ្ឋាភិបាលបានចំណាយ ៤,២% នៃថវិកាសរុបរបស់ខ្លួន ទៅលើវិស័យអប់រំ ហើយអត្រានេះឡើងដល់ ១៥,២% ក្នុងឆ្នាំ១៩៦០។ កូរ៉េខាងត្បូងក៏បានបង្កើតមូលនិធិពិសេសមួយ និងបែងចែកចំណូលពន្ធថែមទៀត សម្រាប់ជួយទ្រទ្រង់ដល់ការអភិវឌ្ឍកម្មវិធីសិក្សា នៅក្នុងទសវត្ស៍១៩៨០ និងទសវត្ស៍១៩៩០។ ម្យ៉ាងទៀត ក្នុងអំឡុងឆ្នាំ១៩៦០ ដល់ ១៩៩០ រដ្ឋាភិបាលបានបែងចែកថវិកាចំនួន ១២,៥% នៃជំនួយអភិវឌ្ឍន៍ ទៅឲ្យវិស័យអប់រំ (Kim et al, 2015) (រូបភាព១)។ ក្រៅពីវិនិយោគជាហិរញ្ញវត្ថុ ផ្នត់គំនិតដែលយល់ឃើញថា វិស័យអប់រំជាឧបករណ៍សម្រាប់ជំរុញឲ្យសង្គមអភិវឌ្ឍ គឺជាកត្តាធំមួយនៃជោគជ័យក្នុងវិស័យអប់រំរបស់កូរ៉េខាងត្បូង (Sorensen 1994, 28)។

រូបភាព១: ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ
គិតជាភាគរយនៃ ផសស ឆ្នាំ២០០០-១២




ចំណាំ: ទិន្នន័យលើប្រទេសកម្ពុជាអាចរកបានតែសម្រាប់ឆ្នាំ២០០០ ដល់ ២០១០
ប្រភព: TheGlobalEconomy.com;
UNESCO www.theglobaleconomy.com/compare-countries/

កម្មវិធីអប់រំថ្នាក់ជាតិរបស់កូរ៉េខាងត្បូង ត្រូវបានរចនារៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងគ្រប់មុខវិជ្ជាទូទៅ រហូតដល់ថ្នាក់ទី១០ ដោយអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ពីថ្នាក់ទី១១ ឡើងទៅ។ បើគិតពីលក្ខណៈស្មើភាពវិញ ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ហាក់ដូច

បានផ្តល់សេរីភាពឲ្យសិស្សក្នុងការជ្រើសរើសផ្នែកសិក្សា រវាងវិទ្យាសាស្ត្រសង្គម ឬវិទ្យាសាស្ត្រធម្មជាតិ។ ប៉ុន្តែ ការដាក់បញ្ចូលសិស្សទៅក្នុងផ្នែកសិក្សាខុសៗគ្នា ដោយផ្អែកលើចំណាប់អារម្មណ៍ជាជាងលើសមត្ថភាព អាចមិនបានផ្តល់នូវភាពដូចគ្នាដ៏ល្អមួយដែលជួយឲ្យគ្រូអាចរចនារៀបចំការបង្រៀន បានកាន់តែប្រសើរ ព្រោះ ឧទាហរណ៍ សិស្សខ្សោយខាងវិទ្យាសាស្ត្រ អាចជ្រើសរើសរៀនមុខវិជ្ជាខាងវិទ្យាសាស្ត្រ។

ទោះបីមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់ក្តី តែក៏អាចមើលឃើញដែរថា ការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅវៀតណាម មានលក្ខណៈជាប្រព័ន្ធ។ គេដាក់បញ្ចូលសិស្សទៅក្នុងផ្នែកសិក្សាផ្សេងៗ ដោយផ្អែកលើលទ្ធផលប្រឡង ឬចំណេះដឹងតាមមុខវិជ្ជា ហើយសាលារៀនមានស្វ័យភាពក្នុងការរចនារៀបចំ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ដើម្បីបំពេញតាមតម្រូវការរបស់សិស្ស។ ការវិភាគលើលទ្ធផលដែលវៀតណាមសម្រេចបាន ក្នុងគុណភាពការអប់រំបង្ហាញនូវកត្តាជោគជ័យដ៏សំខាន់ពីរ។ ទី១ វៀតណាមមានការប្តេជ្ញាចិត្តអស់ជាច្រើនទសវត្សរ៍មកហើយ ក្នុងការធ្វើវិនិយោគលើវិស័យអប់រំ ដើម្បីដោះស្រាយបញ្ហាអនក្ខរកម្ម បង្កើនអត្រាចុះឈ្មោះចូលរៀន និងកំណត់ស្តង់ដាអប្បបរមាសម្រាប់ការអប់រំទូទាំងប្រទេស។ ទី២ គ្រូបង្រៀនវៀតណាមមានគុណសម្បត្តិល្អ ហើយវត្តមានរបស់សិស្សក៏មានកម្រិតខ្ពស់ ( Bodewig 2013 )។

ដូចនៅកូរ៉េខាងត្បូងដែរ ការអនុវត្តការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្សនៅកម្ពុជា ផ្តល់សេរីភាពឲ្យសិស្សក្នុងការរៀបចំកម្មវិធីសិក្សា និងពង្រឹងពង្រីកចំណាប់អារម្មណ៍របស់ខ្លួន ដោយមានផ្តល់នូវផ្នែកសិក្សាផ្សេងៗសម្រាប់ឲ្យជ្រើសរើស។ វិធីនេះបានសម្រាលបន្ទុកនៃការរៀនមុខវិជ្ជាច្រើនពេក ក្នុងនោះមានមុខវិជ្ជាខ្លះ សិស្សមិនសូវចាប់អារម្មណ៍ទេ នៅឆ្នាំបញ្ចប់ថ្នាក់វិទ្យាល័យ។ សិស្សក៏អាចផ្តោតបានកាន់តែច្រើនថែមទៀត ទៅលើមុខវិជ្ជាជាជំនាញឯកទេសរបស់ខ្លួន។ ជាចំណុចអវិជ្ជមានវិញ កម្ពុជានៅតែខ្វះយន្តការសម្រាប់អនុវត្ត ប្រព័ន្ធនៃការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស របស់ខ្លួន។ ការធានាឲ្យមានធនធានគ្រប់គ្រាន់ និងគ្រូបង្រៀនសមស្របល្អតាមមុខវិជ្ជា នៅតែជាបញ្ហាសំខាន់នៅថ្នាក់មធ្យមសិក្សា ជាពិសេសសម្រាប់មុខវិជ្ជាជំនាញវិជ្ជាជីវៈ ដែលនៅឆ្នាំ១៩៩៩ មានអត្រាសមស្របល្អកម្រិតទាបបំផុតត្រឹម ៥ ទៅ ២០%។ ផ្ទុយទៅវិញ មុខវិជ្ជាស្នូល ដូចជាគណិតវិទ្យា ភាសាខ្មែរ និងវិទ្យាសាស្ត្រ មានអត្រាសមស្របល្អពី ៨៥ ទៅ ៩៥% ( UNESCO-IBE 2011 )។

ភស្តុតាងពីប្រទេសមួយទៅប្រទេសមួយបង្ហាញថា គោលនយោបាយបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស គួរផ្តល់សារៈសំខាន់ ដល់ការបង្កើនចំណាប់អារម្មណ៍ និងទំនុកចិត្តរបស់សិស្ស ក្នុងមុខវិជ្ជាណាមួយ ព្រមទាំងការវាយតម្លៃជាញឹកញាប់លើការរីកចម្រើន និងចំណេះដឹងរបស់សិស្សក្នុងមុខវិជ្ជានោះ។ ដើម្បីកំណត់ថា ការវាយតម្លៃគួរញឹកញាប់ប៉ុណ្ណា និងអ្នកណាគួរធ្វើការបែងចែកសិស្សទៅតាមផ្នែកសិក្សាផ្សេងៗ គេត្រូវគិតគូរជាសំខាន់ថាតើគោលនយោបាយបែងចែកតាមសមត្ថភាពឬចំណូលចិត្តសិស្ស គួរមានលក្ខណៈយ៉ាងណា និង តើគួរចាប់ផ្តើមអនុវត្តពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ ឬវិទ្យាល័យ។ ឧទាហរណ៍ ដោយសារសិង្ហបុរីអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស តាំងពីបឋមសិក្សា (ថ្នាក់ទី៥) ដូច្នេះ ការចូលរួមពីឪពុកម្តាយសំខាន់ណាស់ ក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសមស្របបំផុតទៅនឹងសមត្ថភាព និងទេពកោសល្យរបស់កុមារបន្ថែមទៅលើការវាយតម្លៃរបស់សាលារៀន។ ម៉្យាងទៀត ប្រសិនបើ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស ចាប់ផ្តើមនៅអនុវិទ្យាល័យ គឺអាចមិនចាំបាច់មានការចូលរួមពីឪពុកម្តាយទេ ប៉ុន្តែត្រូវមានការវាយតម្លៃលើសមត្ថភាពសិស្ស និងការជួយណែនាំដល់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាដែលគួររៀន។

នៅកម្ពុជា បញ្ហាសំខាន់គឺ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់សន្ទុះចិត្តរបស់សិស្ស ក្នុងការជ្រើសយកផ្នែកសិក្សាណាមួយនោះទេ។ ឧទាហរណ៍ សិស្សអាចជ្រើសរើសយកការសិក្សាផ្នែកវិទ្យាសាស្ត្រ ព្រោះគិតថា អាចបានពិន្ទុខ្ពស់ក្នុងពេលប្រឡងទូទាំងប្រទេស។ ជាការសមហេតុផលដែលគួរគិតថា ដើម្បីអាចសម្រេចចិត្តជ្រើសរើសប្រកបដោយទំនួលខុសត្រូវ និងទទួលបានព័ត៌មានគ្រប់គ្រាន់លើមុខវិជ្ជាដែលគួររៀន សំដៅពង្រឹងសមត្ថភាពរបស់ខ្លួន សិស្សត្រូវមានព័ត៌មាន និងការណែនាំពីអ្នកមានចំណេះដឹង។ ជាងនេះទៀត គ្រូបង្រៀនក៏ត្រូវចេះបកស្រាយយ៉ាងត្រឹមត្រូវពីចំណេះដឹង និងសមត្ថភាពរបស់សិស្សម្នាក់ៗ ដើម្បីអាចវាយតម្លៃពីសមត្ថភាព និងសក្តានុពលរបស់សិស្ស និងជួយណែនាំសិស្សក្នុងការជ្រើសរើសមុខវិជ្ជាឲ្យបានត្រឹមត្រូវ។

កម្ពុជា គួរវាយតម្លៃលើផ្នែកសិក្សានីមួយៗ ដើម្បីវាស់វែងប្រសិទ្ធភាពក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស និងស្វែងរកមធ្យោបាយពង្រឹងគុណភាពការអប់រំជាទូទៅ។ ម៉្យាងទៀត គួរមានការពិនិត្យវិភាគលើបទពិសោធន៍របស់ប្រទេសឯទៀត ក្នុងការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស និងកសាងកម្មវិធីសិក្សា ដើម្បីកំណត់កម្រិតគោលនៃគុណភាពអប់រំ និងអាចកែសម្រួលរបៀបអនុវត្តរបស់បរទេស ឲ្យវាសមស្របទៅតាមបរិបទ និងវប្បធម៌របស់កម្ពុជា។ ប្រព័ន្ធអប់រំនៅកម្ពុជា ក៏គួរគិតគូរលើកស្ទួយឲ្យមានសាលារៀនសម្រាប់អ្នកពូកែ ដើម្បីឲ្យសិស្សដែលមានទេព្យកោសល្យ និងសមត្ថភាពល្អខាងវិទ្យាសាស្ត្រ អាចប្រើសក្តានុពលរបស់ខ្លួនបានច្រើនជាអតិបរមា។

សំខាន់បំផុតត្រូវមានការស្រាវជ្រាវថែមទៀត ដើម្បីពិនិត្យពីការអនុវត្ត ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស នៅតាមវិទ្យាល័យនៅកម្ពុជា ដើម្បីកសាងគោលនយោបាយអប់រំឲ្យបានត្រឹមត្រូវ និងពង្រឹងគុណភាពអប់រំ។ ឧទាហរណ៍ ការសិក្សាសាកល្បងសម្រាប់ត្រួតពិនិត្យដោយចៃដន្យ អាចមានប្រយោជន៍សម្រាប់វាយតម្លៃពីប្រសិទ្ធភាពនៃ ការអនុវត្ត ការបែងចែកតាម

សមត្ថភាព ឬចំណូលចិត្តសិស្ស។ ការសិក្សាបន្ថែមគួរពិនិត្យជាសំខាន់លើ ស្វ័យភាពនៃសាលារៀន តួនាទីរបស់នាយកសាលា និងគ្រូបង្រៀន និង ឥទ្ធិពលនៃកត្តាទាំងនេះ ទៅលើគុណភាពការអប់រំដែលប្រើប្រព័ន្ធ ការបែងចែកតាមសមត្ថភាព ឬចំណូលចិត្តសិស្ស។

## ឯកសារយោង


Bodewing, Christian. 2013. “What Explains Vietnam’s Stunning Performance in PISA 2012?” http://blogs.worldbank.org/eastasiapacific/what-explains-vietnam-s-stunning-performance-pisa-2012.

Chmielewski, Anna K., Hanna Dumont and Ulrich Trautwein. 2013. “Tracking Effects Depend on Tracking Type: An International Comparison of Students’ Mathematics Self-Concept.” *American Educational Research Journal* 50(5): 925-957.

Choi, Kyong Mi, and Dea Sik Hon.2009. “Gifted Education in Korea: Thee Korean High Schools for the Mathematically Gifted.” *Spring* 32(2): 42-49.

Fredriksen, Birger, and Tan Jee Peng. 2008. “An African Exploration of the East Asian Education Experience.” Washington, DC: World Bank.

Hanushek, Eric A., and Ludger Woessmann. 2006. “Does Educational Tracking Affect Performance and Inequality? Differences-in-Differences Evidence across Countries.” *The Economic Journal* 116: 63-76.

Kam, Ho W., and S. Gopinathan. 1999. “Recent Developments in Education in Singapore.” *School Effectiveness and School Improvement* 10(1): 99-117.

Kim, Jinhee, Woojin Cho, Mugyeong Moon, Hyeyoung Park, Ji Min Cho, Ju-Hyoung Park, Yunjeong Choi and Jieun Song. 2015. *Education for All 2015 National Review Report*: *Republic of Korea.* http://unesdoc.unesco.org/images/0022/002297/229721E.pdf.

Kim, Taejong, Ju-Ho Lee and Young Lee. 2003. *Mixing versus Sorting in Schooling: Evidence from the Equalization Policy in South Korea.* KDI School Working Paper Series 03-07. doi.org/10.2139/ssrn.482962.

Ministry of Education, Singapore. 2016a. “Subject-based Banding: Catering to Your Child’s Abilities.” www.moe.gov.sg/education/primary/subject-based-banding.

Ministry of Education, Singapore. 2016b. “Secondary School Courses.” 2015. www.moe.gov. sg/education/secondary/secondary-school-courses.

MOEST (Ministry of Education, Science and Technology), Korea. 2008. “The School Curriculum of The Republic of Korea.” http://gangwonepik.weebly.com/uploads/1/3/8/5/ 13851570/national_school_curriculum-english2008.pdf.

MOEYS (Ministry of Education Youth and Sport), Cambodia. 2004. *Policy for Curriculum Development 2005-2009*. www.moeys.gov.kh/en/press-releases/policy-for-curriculum-development-2005-2009.html#.WEdvWrJ96Uk.

Nuffic (Netherlands Organisation for International Cooperation in Higher Education). 2013. “Country Model – South Korea.” Country module: Evaluation of foreign degrees and qualification in the Netherlands. www.epnuffic.nl/en/publications/find-a-publication/ education-system-south-korea.pdf.

OECD (Organisation for Economic Co-operation and Development). 2011. *Lessons from PISA for the United States, Strong Performers and Successful Reformer in Education*. Paris: OECD Publishing. dx.doi.org/10.1787/9789264096660-en.

OECD. 2014. “Singapore.” In *PISA 2012 Results: Creative Problem Solving (Volume V)*: *Students’ Skills in Tacking Real-Life Problems*. Paris: OECD Publishing. dx.doi.org/10. 1787/9789264208070-16-en.

OECD. 2014. “PISA 2012: Results in Focus.” www.oecd.org/pisa/keyfindings/pisa-2012-results-overview.pdf.

OECD. 2016. “PISA High Performers: Singapore.” Country Note. www.oecd.org/pisa/PISA-2015-singapore.pdf.

Sorensen, Clark W. 1994. “Success and Education in South Korea.” *Comparative Education Review* 38(1): 10-35.

UNESCO. 2007. *Secondary Education Regional Information Base: Country Profile – Viet Nam.* Bangkok: UNESCO. www.uis.unesco.org/Library/Documents/Viet%20Nam.pdf.

UNESCO-IBE. 2011. “World Data on Education.” 7th edition, 2010/11. www.ibe.unesco.org/ fileadmin/user_upload/Publications/WDE/2010/pdf-versions/Cambodia.pdf.

WES (World Education Services). 2012. “Secondary Education in Vietnam.” http://wenr.wes. org/2012/04/secondary-education-in-vietnam.



## Cambodia Development Review—2017 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.